ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# កំណត់ហេតុ

## កិច្ចប្រជុំពិភាក្សាការលើកឡើងរបស់អង្គការសហប្រជាជាតិ ស្តីពីការកើនឡើងនូវការជួញដូរមនុស្សនៅកម្ពុជា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងតំណាងអង្គការសហប្រជាជាតិប្រចាំកម្ពុជា

ថ្ងៃចន្ទ ដប់រោច ខែស្រាពណ៍ ចត្វាស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបប្រាំមួយ ត្រូវនឹងថ្ងៃទីម្ភៃពីរ ខែសីហា ឆ្នាំពីរពាន់ម្ភៃពីរ កិច្ចប្រជុំពិភាក្សា ការលើកឡើងរបស់អង្គការសហប្រជាជាតិ ស្តីពីការកើនឡើងនូវការជួញដូរមនុស្សនៅកម្ពុជា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងតំណាងអង្គការសហប្រជាជាតិប្រចាំកម្ពុជា ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពីភាគីកម្ពុជារួមមាន៖

១.ឯកឧត្តម កេង សុម៉ារិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌

២.ឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការ ក្រសួងការងារបណ្តុះ បណ្តាលវិជ្ជាជីវៈ

៣.ឯកឧត្តម ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន

៤.លោកជំទាវ បណ្ឌិត សឿ សុជាតា អនុរដ្ឋលេខាធិការ ក្រសួងអប់រំយុវជន និងកីឡា

៥.លោកជំទាវ ឡុង សុផល្លី អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី

៦.លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ

៧.លោក ជ័យ រដ្ឋា តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងក្រសួង ស្ថាប័ន និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធមួយចំនួនទៀត

ខាងភាគីប្រតិភូតំណាងពីអង្គការសហប្រជាជាតិប្រចាំកម្ពុជា រួមមាន៖

១.លោក Sardar Umar Alam ប្រធានបេសកកម្មរបស់អង្គការ សហប្រជាតិប្រចាំកម្ពុជា

២.លោកស្រី Roueida El Hage តំណាង OHCHR

៣.លោកស្រី Allissar Charker ប្រធានតំណាងអចិន្ត្រៃយ៍អង្គការ UNDP

៤.លោកស្រី Kristin Parco ប្រធានបេសកកម្ម អង្គការIOM

៥. លោកស្រី Mariana Garofalo ប្រធាន នៃកិច្ចការពារកុមារ អង្គការ UNICEF

៦. លោកស្រី Suman Khaka អ្នកជំនាញកិច្ចការពារ កុមារ អង្គការ UNICEF

៧.លោក Oeung Jeudy អ្នកសម្របសម្រួលអចិន្ត្រៃយ៍ នៃការិយាល័យអង្គការសហប្រជាជាតិ ។

៨.លោក ទុន សោភ័ណ្ឌ អ្នកសម្របសម្រួលអង្គការ ILO

៩.លោក ថា សារ៉ាវុធ តំណាងអង្គការ UNDP

ជាកិច្ចចាប់ផ្តើម នៃកិច្ចប្រជុំពិភាក្សា **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់គណៈប្រតិភូតំណាងអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងវត្តមាន ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ លោកជំទាវ នាយឧត្តមសេនីយ៍ អគ្គស្នងការរងនគរបាលជាតិ ឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងក្រសួង ស្ថាប័នទាំងអស់ដែលអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សានាថ្ងៃនេះ ។

**លោក** Sardar Umar Alam ប្រធានបេសកកម្មរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា និងជាប្រធានដឹកនាំប្រតិភូ ដោយបានលើកឡើងថា សូមអរគុណចំពោះការឆ្លើយតបរបស់ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ លើលិខិតដែលបានស្នើដោយអង្គការសហប្រជាជាតិ បន្ទាប់មកក៏មានការណែនាំសមាសភាព ពីតំណាងភាគីអង្គការសហប្រជាជាតិ ។ លោក Sardar Umar Alam បានលើកឡើងបន្តថា កិច្ចប្រជុំថ្ងៃនេះ គឺជាកិច្ចប្រជុំដ៏មានសារៈសំខាន់ដែលយើងត្រូវជជែកគ្នាត្រង់ទៅត្រង់មក និងបើកចំហរអំពីស្ថានភាពអំពើជួញដូរមនុស្សនៅប្រទេសកម្ពុជា ហើយក៏ជាការឆ្លុះបញ្ចាំងអំពីភាពជាដៃគូរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា ដូចលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ បានជ្រាបរួចហើយថាមានទីភ្នាក់ងារ នៃអង្គការសហប្រជាជាតិមួយចំនួន បានរួមសហការជាដៃគូជាមួយរដ្ឋាភិបាលក៏ដូចជាគណៈកម្មាធិការជាតិ និងក្រសួង ស្ថាប័នមួយចំនួនលើការងារជួញដូរមនុស្សនេះ ហើយអង្គការសហប្រជាជាតិ ក៏បានដឹងផងដែរថា រដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាពមួយចំនួនដើម្បីធ្វើការទប់ស្កាត់អំពើជួញដូរមនុស្សនៅកម្ពុជា ។ លោក Umar បានបញ្ជាក់ថា ដូចខ្លឹមសារដែលអង្គការសហប្រជាជាតិបានផ្ញើជូន លោកជំទាវ ក៏ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន គឺជាការព្រួយបារម្ភរបស់អង្គការសហប្រជាជាតិ ជាពិសេសចំពោះព័ត៌មានដែលយើងទទួលបានកន្លងមកពាក់ព័ន្ធការបង្ខាំងមនុស្ស និងបង្ខំមនុស្សឲ្យធ្វើការ ដែលជាការព្រួយបារម្ភ និងគួរឲ្យកត់សម្គាល់ ហើយចំនួនជនរងគ្រោះក្នុងករណីនេះក៏មានការកើនឡើងផងដែរ ចំពោះអង្គការសហប្រជាជាតិបញ្ហាជួញដូរមនុស្ស គឺប៉ះពាល់ដល់សិទ្ធិមនុស្ស និងសេរីភាពមួយចំនួន ពាក់ព័ន្ធនឹងការប្រើមនុស្សដោយបង្ខំ ឬអំពើទាសភាពមួយចំនួនទៀត ។ លោក Umar បានបន្តថា ដូចដែល លោកជំទាវ បានជ្រាបហើយថាមានប្រទេសដៃគូ និងអង្គការអន្តរជាតិមួយចំនួនក៏បានលើកឡើងអំពីការព្រួយបារម្ភនេះផងដែរ ជាពិសេសជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ ហើយយើងក៏សូមកោតសរសើរចំពោះក្រសួងមហាផ្ទៃ ដែលបានយកចិត្តទុកដាក់ និងព្រួយបារម្ភចំពោះបញ្ហានេះ ដូចជាការចាត់វិធានការបង្ក្រាប ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស ។ លោក Umar Alam បានលើកឡើងបន្តថា មានការពាក់ព័ន្ធនឹងកាតព្វកិច្ចអន្តរជាតិដែលប្រទេសកម្ពុជា បានទទួលស្គាល់នូវកតិកាសញ្ញាអន្តរជាតិមួយចំនួន ដូច្នេះ កម្ពុជាត្រូវមានកាតព្វកិច្ចក្នុងការគោរពសិទ្ធិមនុស្សទាំងអស់នោះ ជាពិសេសការបង្ការ ការការពារជនរងគ្រោះរងគ្រោះដោយអំពើជួញដូរមនុស្ស ក៏ដូចជាការផ្តន្ទាទោសជនល្មើសដើម្បីធានាបាននូវយុត្តិធម៌ ។ លោក Umar បានបញ្ជាក់ថា អំពើជួញដូរមនុស្ស គឺជាបញ្ហាសកល ដែលឆ្លងដែនពីប្រទេសមួយទៅប្រទេសមួយ មិនមែនប្រទេសកម្ពុជាទេដែលជួបប្រទះបញ្ហានេះ មានប្រទេសជាច្រើនក៏បានជួបនូវបញ្ហានេះផងដែរ ។ លោក ក៏បានបញ្ជាក់ម្តងទៀតថា ចំពោះកិច្ចប្រជុំថ្ងៃនេះ គឺយើងមិនត្រឹមតែពិភាក្សាគ្នានូវបញ្ហាចំពោះមុខដែលយើងបានឃើញប៉ុណ្ណោះទេ គឺអង្គការសហប្រជាជាតិនឹងគិតគូរជួយគាំទ្ររដ្ឋាភិបាលកម្ពុជា ចូលរួមដោះស្រាយបញ្ហាជួញដូរមនុស្សនេះ ធ្វើយ៉ាងណាឲ្យស្របទៅនឹងការប្តេជ្ញាចិត្តជាលក្ខណៈអន្តរជាតិរបស់កម្ពុជាផងដែរ ។ ដោយសារមានការរីកចម្រើននូវប្រព័ន្ធបច្ចេកវិទ្យា ទើបធ្វើឲ្យមានការរីកសាយភាយនូវទម្រង់ជួញដូរមនុស្សតាមបែបបរិបទថ្មី គឺគេប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ដើម្បីប្រព្រឹត្តបទល្មើសជួញ

ដែលពីមុនយើងជួបប្រទះតែករណីជួញដូរមនុស្សតាមបែបធម្មតា ដូច្នេះចាំបាច់ត្រូវមានការឆ្លើយជាច្រើនដើម្បីដោះស្រាយនូវបញ្ហានេះ ។

**លោកស្រី** Roueida El Hage តំណាង OHCHR បានលើកឡើងថា កិច្ចប្រជុំក្នុងថ្ងៃនេះមិនមែនត្រឹមតែពិភាក្សាប៉ុណ្ណោះទេ គឺយើងធ្វើការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ដូចលោក Umar បានជម្រាបជូនខាងលើរួចហើយថា អំពើជួញដូរមនុស្ស គឺជាបទល្មើសឆ្លងដែនជាសកល ជាបញ្ហាដ៏ធំ ហើយចំពោះការិយាល័យ OHCHR បានព្យាយាមធ្វើការងារនេះជាច្រើនជាមួយទីបដទៃទៀតផងដែរ ក្នុងការចូលរួមចំណែកក្នុងការទប់ស្កាត់ការរីករាលដាល នៃអំពើជួញដូរមនុស្ស ។ ដោយសារយើងជាអង្គការដែលមានការចូលរួមដោយអន្តររដ្ឋាភិបាល ដូច្នេះអង្គការសហប្រជាជាតិមានអាណត្តិមួយដើម្បីធ្វើការ និងជួយគាំទ្រ ផ្អែកទៅលើទិន្នន័យមួយចំនួនដែលយើងប្រមូលបាន យើងក៏មានការព្រួយបារម្ភចំពោះព័ត៌មានដែលយើងទទួលបានមួយចំនួន ដែលមានតំណាងអង្គការសហប្រជាជាតិ ដូចជា អង្គការ UNICEF UNDP IOM ជាដើម នៅក្នុងការរីករាលដាល នៃជំងឺកូវីដ-១៩ បានធ្វើឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះទម្រង់បទល្មើសជួញដូរមនុស្សជាច្រើន ដែលនាំឲ្យមានផលប៉ះពាល់ដល់ជនរងគ្រោះយ៉ាងធ្ងន់ធ្ងរ ។ លោកស្រី បានបន្តថា យើងក៏បានដឹងផងដែរថា ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលបានទទួលស្គាល់ និងបានចូលរួមច្រើននៅក្នុងក្របខណ្ឌគោលនយោបាយទាំងថ្នាក់តំបន់ និងអន្តរជាតិ ដូចជា Commit ដែលជាទម្រង់មួយ នៃបណ្តាប្រទេសទន្លេមេគង្គ ប្រទេសកម្ពុជា ជាប្រទេសមួយដែលបានចូលរួមគាំទ្រក្នុងក្របខណ្ឌទាំងអស់នេះ យើងសូមកោតសសើរចំពោះកម្ពុជាដែលរៀបចំ និងចូលរួមអនុវត្តនៅក្នុងក្របខណ្ឌនេះផងដែរ ។ លោកស្រី បានបញ្ជាក់ថា ចំពោះព័ត៌មានដែលយើងទទួលបានធ្វើឲ្យមានការព្រួយបារម្ភណាស់ ជាពិសេសព័ត៌មានបង្ខាំងមនុស្ស ក៏ដូចជាការបង្ខំមនុស្សឲ្យធ្វើការ និងមានករណីធ្វើអំពើទារុណកម្មរហូតដល់បាត់បង់ជីវិតផងដែរ ដែលករណីនេះយើងបានដឹងថា គឺជាជនបរទេសដែលអាចហៅបានថាជាឧក្រិដ្ឋជន ដែលមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ និងក្រុងព្រះសីហនុ ។ សូមអរគុណ យើងខ្ញុំចង់ស្តាប់ប្រសាសន៍របស់ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ពាក់ព័ន្ធនឹងផែនការមួយចំនួនរបស់រដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ។

**លោកស្រី** Kristin Parco ប្រធានបេសកកម្មអង្គការ IOM ប្រចាំកម្ពុជា មានមតិនៅក្នុងកិច្ចប្រជុំថា ជាច្រើនឆ្នាំមកហើយប្រទេសកម្ពុជា គឺជាប្រទេសបញ្ជូនកម្លាំងពលកម្មទៅធ្វើការនៅក្រៅប្រទេស ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះសង្កេតឃើញថាប្រទេសកម្ពុជា បានទទួលកម្លាំងពលកម្មពីប្រទេសមួយចំនួនមកធ្វើការវិញ ដែលនេះ គឺជាបញ្ហាប្រឈមមួយដែលត្រូវយកចិត្តទុកដាក់ចំពោះអំពើជួញដូរមនុស្ស ការបង្ខាំង និងការបង្ខំមនុស្សឲ្យធ្វើការ ត្រូវមានវិធានការគ្រប់គ្រងច្បាស់លាស់ដើម្បីបង្ការ ទប់ស្កាត់ការពារជនចំណាកស្រុកមកធ្វើការទាំងអស់នោះ បញ្ហានេះមិនមែនកើតឡើងតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ សូម្បីប្រទេសហ្វីលីពីន ថៃ ជាដើម រួមទាំងមានការនាំមនុស្សចូលមកដោយខុសច្បាប់ផងដែរ ទាំងអស់នេះគ្រាន់តែជាឧទាហរណ៍ សម្រាប់ធ្វើការគិតគូរជាមុនក្នុងការដោះស្រាយបញ្ហា និងជាការទប់ស្កាត់ ។ លោកស្រី បានបន្តថា ដូចយើងបានដឹងរួចមកហើយថា រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះប្រទេសកម្ពុជាបានទទួលមនុស្សមកធ្វើការពីក្រៅប្រទេស ដែលនេះគឺជាបរិបទថ្មី ហើយក៏ជារឿងសំខាន់ យើងអាចធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហាជួញដូរមនុស្សនៅកម្ពុជា ដែលពីមុនមកស្ថានភាពជួញដូរមនុស្សល្អ ប៉ុន្តែបច្ចុប្បន្នស្ថានភាពមិនបានល្អ ដូច្នេះក្នុងនាមអង្គការសហប្រជាជាតិនឹងត្រៀមខ្លួនជានិច្ចក្នុងការចូលរួមគាំទ្រ សម្របសម្រួល និងដោះស្រាយរាល់បញ្ហាជួញដូរមនុស្សនៅកម្ពុជា ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ឆ្លើយតបទៅ ភាគីអង្គការសហប្រជាជាតិថា សូមអរគុណក្នុងការលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជា ហើយកម្ពុជា ក៏ទទួលស្គាល់បញ្ហាដែលកើតមានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនៅកម្ពុជា អាចចាត់ទុកថាជាការចន្លោះប្រហោងរបស់យើង ដែលកន្លងមកនេះ គឺយើងបានសម្លឹងមើលតែខាងក្រៅ ពីព្រោះប្រជាពលរដ្ឋកម្ពុជាបានសម្រេចចិត្តទៅធ្វើការនៅក្រៅប្រទេស ដោយសារស្ថានភាពការងារនៅកម្ពុជា មិនអំណោយផលសម្រាប់ពួកគាត់ ហើយបានសង្កេតឃើញថា ភាពរងគ្រោះសម្រាប់ប្រជាជនកម្ពុជានៅឯក្រៅប្រទេសមានទំហំធំ ប៉ុន្តែទន្ទឹមនឹងនោះព្រះរាជាណាចក្រកម្ពុជា បានធ្វើការប្តេជ្ញាចិត្តដើម្បីជំរុញកម្ពុជាឲ្យរួចផុតពីប្រទេសក្នុងការអភិវឌ្ឍន៍ ទើបកម្ពុជាព្យាយាមបើកឱកាសឲ្យមានការវិនិយោគ ក៏ដូចជាការកសាងនានាដើម្បីផ្តល់ឱកាសការងារដល់ប្រជាជនកម្ពុជា ជាជាងដែលគាត់ស្វែងរកការងារធ្វើដោយប្រថុយប្រថាននៅឯក្រៅប្រទេស ហើយនៅក្នុងសម័យកាល នៃការរីករាលដាលជំងឺកូវីដ-១៩ គឺយើងមានភាពប្រឈមខ្លាំង មិនមែនមានតែកម្ពុជាប៉ុណ្ណោះទេ គឺមាននៅគ្រប់បណ្តាប្រទេសទាំងអស់ ដែលធ្វើឲ្យប៉ះពាល់ដល់ជនទេសន្តរប្រវេសន៍ ប្រជាពលរដ្ឋកម្ពុជាត្រូវបានវិលត្រឡប់មកវិញយ៉ាងច្រើនក្នុងរយៈពេលដ៏ខ្លី អំឡុងពេលនោះយើងក៏បានដឹងថាមានមេខ្យល់កំពុងព្យាយាមអូសទាញប្រជាពលរដ្ឋ ដែលស្ថិតក្នុងស្ថានភាពមិនប្រក្រតី ឲ្យវិលត្រឡប់ទៅរកការងារធ្វើនៅឯក្រៅប្រទេស ដែលកំពុងតែមានស្ថានភាពប្រឈម និងគ្រោះថ្នាក់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ហើយរាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញនូវវិធានការជាច្រើនដើម្បីការពារភាពរងគ្រោះរបស់ប្រជាពលរដ្ឋរបស់យើង កំពុងតែឆ្លងកាត់នូវការលំបាក ដែលបានសម្រេចចិត្តទៅធ្វើការទាំងប្រថុយប្រថាននៅឯក្រៅប្រទេស នៅក្នុងពេលនោះក៏មានជនបរទេសមករងគ្រោះនៅកម្ពុជាទៅវិញ ។ **លោកជំទាវ** មានប្រសាសន៍បញ្ជាក់ថា សមត្ថកិច្ចរបស់យើងបានសហការជាមួយសមត្ថកិច្ច នៃប្រទេសពាក់ព័ន្ធ និងជាមួយដៃគូអន្តរជាតិដើម្បីសង្គ្រោះជនរងគ្រោះជាបន្តបន្ទាប់ ដែលក្នុងរយៈពេល ៧ខែដើមឆ្នាំ យើងបានធ្វើការបង្ក្រាប និងសង្គ្រោះជនរងគ្រោះ បានចំនួន ៤៦ ករណី ក្នុងមានជនរងគ្រោះប្រមាណ ៦០០នាក់ មាន១១សញ្ជាតិ និងបានកសាងសំណុំរឿងបញ្ជូនទៅតុលាកាចំនួន ១៧ ករណី បានឃាត់ខ្លួនជនសង្ស័យសរុបចំនួន ៦០នាក់ មានជនជាតិវៀតណាម ចិន ម៉ាឡេស៊ី និងកម្ពុជា សមត្ថកិច្ចយើងបានបញ្ជាក់ថា មានចំនួន ២៩ ករណី មិនមានធាតុផ្សំពាក់ព័ន្ធនឹងការបង្ខាំងមនុស្សខុសច្បាប់ ឬចាប់ជំរិតប៉ុន្តែ គឺជាការវិវាទការងាររវាងបុគ្គលិក និងក្រុមហ៊ុនដូចជាការគេចវេសពីការងារ មិនគោរពកិច្ចសន្យាការងារ ជំពាក់បំណុលក្រុមហ៊ុន ជាដើម... ហើយយើងក៏ទទួលស្គាល់ថា ពិតជាមានករណីបង្ខាំងមនុស្សខុសច្បាប់ ធ្វើទារុណកម្មដែលសមត្ថកិច្ចកម្ពុជា បានសហការជាមួយនឹងសមត្ថកិច្ចប្រទេសពាក់ព័ន្ធដើម្បីចាត់បញ្ជូនជនរងគ្រោះ និងជនល្មើសដើម្បីផ្តន្ទាទោសនៅឯប្រទេសសាមី ។ **លោកជំទាវ** មានប្រសាសន៍បន្តថា ភាពលំបាកក្នុងការគ្រប់គ្រងករណីនេះ ដោយសារមានការទំនាក់ទំនងតាមប្រព័ន្ធអនឡាញមេខ្យល់ជាជនជាតិបរទេសនៅឯប្រទេសក្រៅ ក្នុងករណីដែលយើងបានរកឃើញនូវករណីនីមួយៗ គឺយើងមិនដែលធ្វេសប្រហែសទេ យើងតែងតែចូលរួមបង្ក្រាប និងសង្គ្រោះជនរងគ្រោះជានិច្ច ។ **លោកជំទាវ** មានប្រសាសន៍លើកឡើងថា បញ្ហាជួញដូរមនុស្ស គឺជាអាជីពមួយដែលមានការលាក់លៀម និងសម្ងាត់ ដូច្នេះយើងមិនអាចរកឃើញមុនព័ត៌មានដែលបានផ្តល់ឲ្យយើងនោះទេ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី តាមរយៈការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលតាមរយៈក្រសួងមហាផ្ទៃ ក៏ដូចជាគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវវិធានការបន្ទាន់មួយ ក្នុងការប្រតិបត្តិការស្វែងរកបទឧក្រិដ្ឋជួញដូរមនុស្សដែលបាន និងកំពុងលាក់លៀមនៅក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា កន្លងមកនេះអ្វីដែលយើងបានទទួលពីជនរងគ្រោះ ក៏ដូចជាសេចក្តីរាយការណ៍ផ្សេងៗថា បទល្មើសទាំងនេះមានបង្កប់នៅក្នុងអាជីវកម្មមួយចំនួន ដែលយើងអាចកំណត់បានទៅលើតំបន់សំខាន់ៗដែលយើងបានដាក់

ការសង្ស័យដោយចាប់ផ្តើមពីខេត្តព្រះសីហនុ យើងនឹងចុះធ្វើការប្រតិបត្តិការលើបញ្ហានេះ ដូច្នេះសូមខាងដៃគូពាក់ព័ន្ធ និងមហាជនមេត្តារង់ចាំបន្តិចអំពីលទ្ធផល និងព័ត៌មានពិតប្រាកដ នៃបទល្មើសទាំងនោះ បន្ទាប់មកយើងនឹងផ្តល់ជូននូវព័ត៌មានត្រឡប់ទៅវិញ ក្នុងពេលនេះកម្ពុជា នៅមិនទាន់អាចឆ្លើយតបថាមានទីតាំងប៉ុន្មាន នៅកន្លែងណាខ្លះដែលលាក់បំពួន? យើងនឹងធ្វើការស្រាវជ្រាវស្វែងរកព័ត៌មានច្បាស់លាស់ រួចយើងនឹងធ្វើការបង្ក្រាប និងសង្គ្រោះ យើងបានទទួលព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយជាច្រើន និងពីបណ្តាប្រទេសមួយចំនួនពាក់ព័ន្ធនឹងភាពរងគ្រោះនៅកម្ពុជា ប៉ុន្តែយើងនៅមិនទាន់ដឹងអំពីទីតាំង និងមានទំហំប៉ុណ្ណានោះទេ ។ **លោកជំទាវ** មានប្រសាសន៍បន្ថែមថា ការពិតទៅយើងមិនចង់ឲ្យមានការបែកធ្លាយអំពីព័ត៌មាន នៃការចុះបង្ក្រាប និងជួយជនរងគ្រោះរបស់សមត្ថកិច្ចជំនាញមុនការធ្វើប្រតិបត្តិការនោះទេ ពីព្រោះអាចបណ្តាលឲ្យជនល្មើសដឹងមុននឹងមានការផ្លាស់ប្តូរទីតាំង ដែលជាហេតុនាំឲ្យមានផលលំបាក ក្នុងការស្វែងរកទីតាំងរបស់ជនល្មើស ប៉ុន្តែអ្វីទាំងនោះត្រូវបានមហាជនទាមទាចង់ដឹងថាតើសមត្ថកិច្ចយើងអនុវត្ត ឬមានចំណាត់ការយ៉ាងណា? ដល់ណាហើយ? ពេលយើងធ្វើការផ្សព្វផ្សាយ សមត្ថកិច្ចនឹងជួបការលំបាកក្នុងការតាមរក និងបង្ក្រាបទីតាំងរបស់ជនល្មើសទាំងនោះ ប៉ុន្តែប្រសិនបើមានបទល្មើសទាំងនោះកំពុងលាក់បំពួននៅក្នុងព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថាយើងនឹងរកឃើញក្នុងពេលឆាប់ៗ ។ **លោកជំទាវ** បានបន្តថា រដ្ឋាភិបាលប្រទេសកម្ពុជាតែងតែគិត កម្ពុជាមិនមែនជាកន្លែងដែលមានជនល្មើសជួញដូរមនុស្ស និងបទឧក្រិដ្ឋផ្សេងៗនោះទេ គឺជាប្រទេសដែលមានសុខសុវត្ថិភាព យើងតែងតែគិតថាប្រជាជនកម្ពុជា គឺត្រូវបានរងគ្រោះនៅឯក្រៅប្រទេស ដូច្នេះទើបធ្វើឲ្យមានការខ្វះចន្លោះនៅក្នុងបញ្ហានេះ ហើយពេលនេះយើងបានមើលឃើញថា ពិតជាមានករណីជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជាមែន ដូច្នេះយើងនឹងធ្វើការប្រតិបត្តិការលើការងារនេះជាបន្តបន្ទាប់ ។ **លោកជំទាវ** មានប្រសាសន៍ថ្លែងអំណរគុណចំពោះអង្គការសហប្រជាជាតិ ក៏ដូចជាដៃគូជាតិ អន្តរជាតិ និងបណ្តាប្រទេសពាក់ព័ន្ធដែលតែងតែគាំទ្រ ស្ម័គ្រចិត្តជួយលើការប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ។ លោកជំទាវ មានប្រសាសន៍អំពីយុទ្ធសាស្ត្រការងារ និងរចនាសម្ព័ន្ធការងារនៅក្នុងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដូច្នេះពាក់ព័ន្ធសកម្មភាពដែលយើងបានរកឃើញ និងគ្រោងធ្វើនៅក្នុងពេលបច្ចុប្បន្នេះ គឺ ទី១.ការពិនិត្យឡើងវិញនូវផែនការសកម្មភាពពីពេលនេះរហូតដល់ឆ្នាំ២០២៣ ដែលបានពិភាក្សាជាមួយក្រសួងស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធដែលយើងនឹងគ្រោងធ្វើសិក្ខាសាលាធំមួយនៅក្នុងអំឡុងខែតុលា ឆ្នាំ២០២២ ខាងមុខនេះ ។ ទី២.ជំរុញអនុវត្តលើអនុសាសន៍នានាដែលបានលើកដោយសហរដ្ឋអាម៉េរិកពាក់ព័ន្ធនឹងចំណុចខ្វះចន្លោះដែលយើងមានកន្លងមក ។ ទី៣.យើងបានធ្វើផែនការប្រតិបត្តិការស្វែងរកបទល្មើសដែលបាន និងកំពុងលាក់បំពួននៅក្នុងប្រទេសកម្ពុជា ទី៤.បន្ទាប់មកទៀតយើងនឹងធ្វើការពិភាក្សាជាមួយអ្នកជំនាញដៃគូទាំងឡាយ ថាតើក្នុងច្បាប់របស់យើងមានចំណុចខ្វះចន្លោះអ្វីខ្លះ? ដើម្បីរួមបញ្ចូល ឬចែងឲ្យច្បាស់អំពីចំណុចដែលទាក់ទងនឹងបទល្មើសជួញដូរមនុស្ស ។ ដូចឯកឧត្តម លោកជំទាវបានជ្រាបហើយថា បទល្មើសដែលបានរកឃើញកន្លងមក គឺគេផ្តោតលើបទល្មើសជួញដូរមនុស្ស ប៉ុន្តែយើងមានច្បាប់របស់យើងពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដោយផ្អែកទៅលើពិធីសារអន្តរជាតិ ដូច្នេះបើយើងរកឃើញថាបទល្មើសនោះជាប់ពាក់ព័ន្ធជាមួយបទល្មើសជួញដូរមនុស្ស យើងនឹងដាក់បំពេញបន្ថែម កន្លងមកយើងក៏មានបទពិសោធន៍ពាក់ព័ន្ធបទល្មើសតាមប្រព័ន្ធអនឡាញ ប៉ុន្តែមិនសុទ្ធតែជាបទល្មើសជួញដូរមនុស្សទេ ដូច្នេះយើងសូមស្វាគមន៍ជាមួយអ្នកជំនាញទាំងឡាយក្នុងការចូលរួមសហការ ផ្តល់ជាមតិយោបល់ពាក់ព័ន្ធនឹងបញ្ហានេះ ជាពិសេសពាក់ព័ន្ធបទល្មើសថ្មីៗ ហើយយើងនឹងធ្វើការផ្តោតឲ្យចំគោលដៅលើការងារបង្ការទប់ស្កាត់ បន្ថែមអ្វីទៅលើបទល្មើសក្នុងកម្ពុជាដែរ ។ **លោកជំទាវ** មានប្រសាសន៍បន្ថែមថា នឹងធ្វើការអំពាវនាវទៅបណ្តាប្រទេសនៅក្នុងតំបន់ ក៏ដូចជាអន្តរជាតិ ដើម្បីឲ្យមានការបង្ការទប់ស្កាត់ដូចគ្នា ជៀសវាងមានជនបរទេសមក

រងគ្រោះនៅកម្ពុជាបន្តទៀត យើងធ្វើការផ្តោតលើកិច្ចការពារជនរងគ្រោះ ពីព្រោះជនរងគ្រោះអាចមានទាំងជនបរទេស និងពលរដ្ឋកម្ពុជា ដោយឡែកជនរងគ្រោះជាជនបរទេសភាគច្រើន ត្រូវបានគេល្បួងបោកបញ្ឆោតចូលមកកម្ពុជា ដូច្នេះយើងត្រូវធ្វើយ៉ាងណាដើម្បីគ្រប់គ្រង បង្ការ ការពារ និងដាក់ទោសចំពោះពួកគេដែលជាជនបរទេសបើយើងរកឃើញថាមានជាប់ពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស ។ **លោកជំទាវ** មានប្រសាសន៍បន្តថា នឹងធ្វើការស្នើសុំទៅអង្គការសហប្រជាជាតិឲ្យមានការធ្វើការជាមួយប្រទេសពាក់ព័ន្ធទាំងឡាយ នៅពេលរដ្ឋាភិបាលគាត់មានការព្រួយបារម្ភ អំពីប្រជាជនគាត់មកធ្វើការនៅប្រទេសកម្ពុជា ដើម្បីងាយស្រួលគិតជាមួយគ្នាថាតើយើងត្រូវធ្វើបែបណា? ពីព្រោះករណីខ្លះមានការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានដោយគ្រាន់តែធ្វើការប៉ាន់ស្មាន **ឧទាហរណ៍៖** មានការចុះផ្សាយថាមានជនបរទេសមកធ្វើការនៅក្នុងប្រទេសកម្ពុជារាប់ពាន់នាក់ និងបានវិលត្រឡប់ទៅវិញតែប៉ុន្មានភាគរយតែប៉ុណ្ណោះ ដូច្នេះមានន័យថាជនបរទេសដែលមិនទៅ គឺជាជនរងគ្រោះ ត្រង់ចំណុចនេះហើយទើបស្នើឲ្យមានការសហការធ្វើការជាមួយគ្នាដើម្បីរកឲ្យឃើញអំពីចំនួនពិតប្រាកដរបស់ពលករស្របច្បាប់ និងមិនស្របច្បាប់ ។ **លោកជំទាវ** មានប្រសាសន៍បញ្ជាក់ថា កម្ពុជាពិតជាចង់បានសុខសុវត្ថិភាពសម្រាប់អ្នកដែលមករស់នៅធ្វើការងារក្នុងប្រទេសរបស់ខ្លួន ទាំងជនជាតិខ្មែរ និងជនបរទេស ដូច្នេះអ្វីដែលជាការចូលរួម នៃបណ្តាប្រទេសនានា ក៏ដូចជាអង្គការដៃគូពាក់ព័ន្ធ កម្ពុជាសូមស្វាគមន៍ក្នុងការផ្តល់ជាមតិយោបល់ គាំទ្រដើម្បីសុវត្ថិភាពទាំងអស់គ្នា ។

**លោក** Sardar Umar Alam ប្រធានបេសកកម្មរបស់អង្គការសហប្រជាតិប្រចាំកម្ពុជា បានសម្តែងការរីករាយចំពោះវិធានការ ដែលនឹងអាច ផ្តល់នូវព័ត៌មានពិតពីកម្ពុជា ក៏ដូចជាបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងមុះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ លោក Umar Alam ចង់ដឹងថា តើគណៈកម្មាធិការជាតិ មានគម្រោង ឬផែនការអ្វីខ្លះដើម្បីឆ្លើយតបទៅនឹងស្ថានភាពនាពេលបច្ចុប្បន្ន? ដើម្បីឲ្យអង្គការសហប្រជាជាតិ អាចចូលរួមសហការ និងគាំទ្រលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ លោក ក៏បានបញ្ជាក់ថា ក្រុមការងារអន្តរក្រសួងទាំង៦ នៃគណៈកម្មាធិការជាតិ ក៏មានទំនាក់ទំនងជាមួយភ្នាក់ងាររបស់អង្គសហប្រជាជាតិផងដែរដែលបានកំពុងធ្វើការងារនេះ ចំពោះការងារ គឺជាបញ្ហាអន្តរជាតិផងដែរ ហើយអង្គការសហប្រជាជាតិ គឺជាអង្គការអន្តររដ្ឋាភិបាល គឺធ្វើការឲ្យមានទ្វេភាគីនិយម ដូច្នេះយើងនឹងត្រៀមខ្លួនជួយគាំទ្រដល់រដ្ឋាភិបាលកម្ពុជា យើងនឹងធ្វើការពិភាក្សាគ្នារិះរកចំណុចបន្ថែមខ្វះខាត ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ។ លោកបានលើកឡើងថា ពាក់ព័ន្ធនឹងប្រតិបត្តិការស្រាវជ្រាវបង្ក្រាបរបស់រដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិមានសហការី ដើម្បីជួយប្រសិនបើកម្ពុជាត្រូវការ ។

**លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ដោយបានស្នើទៅក្រុមអង្គការសហប្រជាជាតិ នូវចំណុចមួយចំនួនដូចខាងក្រោម ៖

១.ក្នុងតួនាទីរបស់អង្គការសហប្រជាជាតិ សូមជួយធ្វើជាអ្នកទំនាក់ទំនងសម្របសម្រួល (Coordinator) សម្រាប់ប្រទេសពាក់ព័ន្ធ ទាំងប្រទេសមានកិច្ចព្រមព្រៀង និងគ្មានកិច្ចព្រមព្រៀង ក្នុងតំបន់ ដើម្បីអាចសហការក្នុងការប្រឆាំងបទល្មើសរួមគ្នា និងបង្កើតកម្មវិធីបង្ការទប់ស្កាត់ និងកិច្ចការពារជនរងគ្រោះ ដែលមានលក្ខណៈជាស្តង់ដារួមគ្នា ងាយស្រួលក្នុងការអនុវត្ត ។

២.សូមផ្តល់ជំនួយបច្ចេកទេស ក្នុងការកំណត់រកបទល្មើសថ្មី និងការកែសម្រួលចំណុចខ្វះចន្លោះ នៃមាត្រាច្បាប់ ដើម្បីឲ្យប្រាកដថា តើបទល្មើសបែបណា ដែលហៅថា អំពើជួញដូរមនុស្ស ឬជាបទល្មើសពាក់ព័ន្ធ ជៀសវាងការដាក់បន្ទុកចោទប្រកាន់ដោយមិនមានឯកសារច្បាប់ជាបង្អែក ។

៣.គណៈកម្មាធិការជាតិ កំពុងដាក់វិធានការអនុវត្តផែនការបង្កើនកិច្ចប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទក្នុងទ្រង់ទ្រាយធំ នៅទូទាំងប្រទេស ដើម្បីលុបបំបាត់បទល្មើសដែលលាក់បង្កប់ក្នុងអាជីវកម្មនានា ចំពោះលទ្ធផលដែលទទួលបាន នឹងធ្វើការផ្សព្វផ្សាយ ទូលំទូលាយ ដល់សាធារណៈជន និងប្រទេសនានា ។

៤.គណៈកម្មាធិការជាតិ កំពុងរៀបចំកែសម្រួលផែនការសកម្មភាព ឆ្នាំ២០២២-២០២៣ ដោយពិនិត្យ និងដាក់បញ្ចូលអនុសាសន៍របស់សហរដ្ឋអាម៉េរិក អំពីផែនការថ្មីៗក្រសួង ស្ថាប័ន បាន និងកំពុងរៀបចំ ។

៥.យុទ្ធនាការអប់រំផ្សព្វផ្សាយ តាមរយៈវេទិកាអន្តរសាសនា ឬទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នឹងត្រូវបានផ្តោតលើបច្ចុប្បន្នភាព នៃបញ្ហា និងការបង្ការទប់ស្កាត់នូវអំពើជួញដូរមនុស្ស តាមរូបភាពផ្សេងៗ ដែលត្រូវមានការប្រុងប្រយ័ត្នខ្ពស់ ។

៦.សូមអង្គការសហប្រជាជាតិ ជួយតាមដានការអនុវត្ត កិច្ចព្រមព្រៀង ឬអនុស្សរណៈទ្វេភាគី ពហុភាគីដែលមានស្រាប់ និងជួយគាំទ្រដល់កិច្ចពិភាក្សានានា ជាមួយបណ្តាប្រទេសពាក់ព័ន្ធ ក្នុងដំណើរការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ជាក់ស្តែង គណៈប្រតិភូកម្ពុជា នឹងទៅជួបពិភាក្សាជាមួយភាគីថៃ អំពីការពិនិត្យសម្រេច និងចុះហត្ថលេខាលើនីតិវិធីប្រតិបត្តិស្តង់ដារ នៃកិច្ចសហការទ្វេភាគីរវាង ព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស ។

ចុងបញ្ចប់ នៃកិច្ចប្រជុំ **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ថ្លែងអំណរគុណចំពោះ គណៈប្រតិភូអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ក៏ដូចជា ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាក្នុងថ្ងៃនេះ ។ លោកជំទាវ បានមានប្រសាសន៍ជូនពរដល់គណៈប្រតិភូអង្គការសហប្រជាជាតិ និងឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងក្រសួង ស្ថាប័នទាំងអស់ ទទួលបាននូវជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

កិច្ចប្រជុំពិភាក្សា បានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងដប់ប្រាំនាទី ថ្ងៃខែឆ្នាំដដែល ។

ថ្ងៃពុធ ១២រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២

**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ទោ. សៅ ស៊ីនួន

ព្រានហើយ
05/09/22

ជូ_ម៉ុនអេង

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបជាដ៏ខ្ពង់ខ្ពស់។

ថ្ងៃ សុក្រ ៧ កើត ៨ ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០២២

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៉ុណ្ណ សំខាន់